# ផែនទីបង្ហាញផ្លូវសម្រាប់គ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់

## “ ចក្ខុវិស័យ និង ផ្លូវឆ្ពោះទៅមុខ ”



CAMBODIA CLIMATE CHANGE ALLIANCE

Implemented by:

Funded by:

ស៊ុយអែត
Sverige

# មាតិកា


១. សេចក្តីផ្តើម 1

២. គោលការណ៍សម្រាប់ការគ្រប់គ្រងជលផលសមុទ្រ 4

៣. ចក្ខុវិស័យតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ 6

៤. បញ្ហាប្រឈម 7

៥. ទិដ្ឋភាពទូទៅនៃផែនទីបង្ហាញផ្លូវ 8

គោលបំណង និងការរៀបចំផែនទីបង្ហាញផ្លូវ 8

យុទ្ធសាស្ត្រនៃការអនុវត្តផែនទីបង្ហាញផ្លូវ 9

គោលដៅយុទ្ធសាស្ត្រទី១ - ការពារ និងស្តារមុខងារជីវរូបសាស្ត្រ រួមមានប្រព័ន្ធអេកូឡូស៊ី 11

ជីវៈចម្រុះ និងធនធានជលផលសមុទ្រសំខាន់ៗក្នុងតំបន់ 11

គោលដៅយុទ្ធសាស្ត្រទី២ - អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមក្នុងតំបន់ឱ្យមានភាពប្រសើរឡើង 13

គោលដៅយុទ្ធសាស្ត្រទី៣ - ពង្រឹងអភិបាលកិច្ចតំបន់ប្រកបដោយប្រសិទ្ធភាពខ្ពស់ 15

គោលដៅយុទ្ធសាស្ត្រទី៤ - ផ្តួចផ្តើមបង្កើត និងអនុវត្តយន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយ

និរន្តរភាព និងការចែករំលែកផលប្រយោជន៍ប្រកបដោយតម្លាភាពក្នុងតំបន់ 17

គោលដៅយុទ្ធសាស្ត្រទី៥ - ពង្រឹងភាពធន់ និងបន្សាំ នឹងការប្រែប្រួលអាកាសធាតុ ដោយប្រើ

សំលេងវិទ្យាសាស្ត្រ និងការកសាងសមត្ថភាពជាអតិបរិមា 19

៦. យន្តការអនុវត្តហិរញ្ញវត្ថុ 20

៦.១. យន្តការនៃការគ្រប់គ្រង 20

៦.២. ប្រភពហិរញ្ញវត្ថុ 22

៦.៣. ការតាមដាន និងវាយតំលៃ 22

# ១ | សេចក្តីផ្តើម

វិស័យជលផលបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍនសេដ្ឋកិច្ចសង្គមជាតិ ជាពិសេសធានាសន្តិសុខស្បៀងនិងអាហាររូបត្ថម្ភ ការលុបបំបាត់ភាពក្រីក្រ និងការការពារបេតិកភណ្ឌធម្មជាតិ។ ជលផលសមុទ្របានរួមចំណែកសរុបប្រមាណ២០ភាគរយនៃផលនេសាទសរុបនៅឆ្នាំ២០១៧។ ទោះជាយ៉ាងណាជលផលសមុទ្រត្រូវបានគម្រាមកំហែងដោយកត្តាធំៗមួយចំនួនដូចជា ការនេសាទហួសកម្រិត ការនេសាទខុសច្បាប់ គ្មានរបាយការណ៍និងគ្មានការអនុញ្ញាត ការបាត់បង់ទីជម្រក និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រជាដើម។ កត្តាទាំងនេះបានជះឥទ្ធិពលអវិជ្ជមានទៅលើអ្នកនេសាទខ្នាតតូច និងគ្រួសារងាយរងគ្រោះនៅតាមតំបន់ ឆ្នេរសមុទ្រដែលពឹងផ្អែកលើការនេសាទសម្រាប់ទ្រទ្រង់ជីវភាព។ ឆ្លើយតបជាមួយស្ថានការណ៍ជាក់ស្តែងរាជរដ្ឋាភិបាលបានដាក់ចេញគោលការណ៍គន្លឹះ និងវិធានការចាំបាច់ ដើម្បីដោះស្រាយបញ្ហាចំពោះមុខឈរលើផលប្រយោជន៍ជាតិវិស័យជលផលសមុទ្រ។

ខេត្តព្រះសីហនុ ក្រោមការគាំទ្រពីរដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍ បានរៀបចំបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រប្រជុំកោះរ៉ុង និងកោះរ៉ុងសន្លឹម នៅឆ្នាំ២០១៦ ដែលជាសញ្ញាវិជ្ជមានដ៏ សំខាន់គាំទ្រដល់ការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យជលផលនៅកម្ពុជា។ ដោយទទួលស្គាល់នូវភាពចាំបាច់ និងសារៈសំខាន់នៃធនធានជលផល និងជីវៈចម្រុះតំបន់ឆ្នេរនិងសមុទ្រ រដ្ឋបាលខេត្តព្រះសីហនុ បានបន្តធ្វើការជាមួយរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខ ប្រមាញ់ និងនេសាទ ក្រោមជំនួយថវិកាពី កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដំណាក់កាលទី៣ (CCCA3) បានផ្តួចផ្តើមនិងគាំទ្ររៀបចំបង្កើតតំបន់ព្រៃកកំពង់ស្នាច់ ជា តំបន់គ្រប់គ្រងជលផលសមុទ្រ ទី២ បន្ទាប់ពីតំបន់គ្រប់គ្រងជលផលសមុទ្រប្រជុំកោះរ៉ុង កោះរ៉ុងសន្លឹម។



ព្រែកកំពង់ស្នាច់ ជាតំបន់ដ៏សក្ដានុពលមួយ ស្ថិតក្នុងស្រុកព្រៃនប់ ហើយស្រុកព្រៃនប់ ត្រូវបានគេស្គាល់យ៉ាងច្បាស់ថា ជា "ឆកវាលរិញ" ដោយសារតែភាពសំបូរបែបនៃធនធានតំបន់ឆ្នេរ ដូចជាព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម ក្ដាម បង្គារ ។ល។ ស្រុកព្រៃនប់ មានព្រែកចំនួន៣សំខាន់ៗ ដូចជា ព្រែកទឹកសាប ព្រែកកំពង់ស្នាច់ និងព្រែកទាល់។ ព្រែកទាំង៣នេះ ដើរតួនាទីសំខាន់ក្នុងការស្ដុកទឹកពីប្រភពផ្សេងៗ ដើម្បីផ្គត់ផ្គង់ដល់ការប្រើប្រាស់ក្នុងស្រុក។ ព្រែកកំពង់ស្នាច់ ជាតំបន់ទេសភាពប្រព័ន្ធអេកូឡូស៊ីល្អបំផុត រួមមានដែននេសាទសហគមន៍តំបន់ឆ្នេរ និងគ្របដណ្ដប់ទៅដោយព្រៃកោងកាងដ៏វិសេសវិសាល។ ព្រែកកំពង់ស្នាច់ ត្រូវបានស្គាល់ថាជាព្រែកប្រភពទឹកដ៏ចំបងសម្រាប់ស្រុកព្រៃនប់ ដែលទទួលទឹកពីដៃស្ទឹងតូច ធំ ចំនួន ១៦ ជាពិសេសស្ទឹងដែលហូរមកពីភ្នំបូកគោ ហើយទឹកព្រែកនេះហូរចាក់ទៅឆកវាលរិញ។ តាមរយៈនៃការស្រាវជ្រាវតំបន់ព្រែកកំពង់ស្នាច់ បានរកឃើញនូវព្រៃកោងកាងចំនួន ៣៩ប្រភេទ ដែលរួមមាន២៣ប្រភេទដាំឡើងវិញ និងចំនួន ១៦ប្រភេទ បានដុះក្នុងតំបន់នេះស្រាប់។ ប្រភេទព្រៃកោងកាងទាំង៣៩ ដុះលាយឡំគ្នាមានប្រមាណ១៥ ទៅ២៥ ប្រភេទ និងមានកំពស់២៥ ម៉ែត្រ និងអង្កត់ផ្ចិត ០.៨០ ម៉ែត្រ។ ក្រៅពីព្រៃកោងកាង ព្រែកកំពង់ស្នាច់ក៏មាននូវស្មៅសមុទ្រ ល្បាប់ភក់ ដែលអំណោយផលដល់ប្រភេទខ្យងសមុទ្រ គ្រែងឈាម និងក្ដាម ជាដើម។ លើសពីនេះទៀត មាននូវសត្វព្រៃ សត្វល្មូន និងសត្វស្លាបជាច្រើនប្រភេទនិងសក្ដានុពលដ៏ពិសេសក្នុងតំបន់នេះ គឺមានទំនប់ការពារទឹកប្រៃប្រវែង ៨៨,៣២ គីឡូម៉ែត្រ សំណង់ទ្វារទឹកចំនួន ៣៦កន្លែង ប្រឡាយប្រវែង ១៣៣ គីឡូម៉ែត្រ បែងចែកជា ០៦ផែន ឬ ហៅថា (ប៉ុលឌែរ) ស្ថិតក្នុងឃុំចំនួន៩ ក្នុងស្រុកព្រៃនប់។



ការបង្កើត និងគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រប្រកបដោយប្រសិទ្ធភាព ជាយន្តការចាំបាច់ដែលរាជរដ្ឋាភិបាលបាននឹងកំពុងប្រតិបត្តិក្នុងអំឡុងពេលមួយទសវត្សរ៍ចុងក្រោយនេះ។ ជាលទ្ធផលតំបន់គ្រប់គ្រងជលផលសមុទ្រចំនួនពីរតំបន់ត្រូវបានបង្កើត និងបីតំបន់គ្រោងនឹងបង្កើតជាបន្តបន្ទាប់នៅតាមបណ្តាខេត្តតំបន់ឆ្នេរសមុទ្រទាំងអស់ នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖

- តំបន់គ្រប់គ្រងជលផលសមុទ្រប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម ខេត្តព្រះសីហនុ បានបង្កើតនៅឆ្នាំ២០១៦ (បានប្រែក្លាយជាឧទ្យានជាតិសមុទ្រកោះរ៉ុង នៅឆ្នាំ ២០១៨)។
- តំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះពោធិ៍និងកោះទន្សាយ ខេត្តកែប បានបង្កើតនៅឆ្នាំ២០១៨។
- តំបន់គ្រប់គ្រងជលផលសមុទ្រនៅព្រែកកំពង់ស្មាច់ ខេត្តព្រះសីហនុ បាននឹងកំពុងរៀបចំបង្កើតនៅឆ្នាំ២០២២។
- តំបន់គ្រប់គ្រងជលផលសមុទ្រព្រែកត្នោត និងត្រពាំងរពៅ ខេត្តកំពត បាននឹងកំពុងរៀបចំបង្កើតនៅឆ្នាំ២០២២។
- តំបន់គ្រប់គ្រងជលផលសមុទ្រប្រជុំកោះស្តេច ខេត្តកោះកុង បាននឹងកំពុងរៀបចំបង្កើតនៅឆ្នាំ២០២២។



# ២ | គោលការណ៍សម្រាប់ការគ្រប់គ្រងជលផលសមុទ្រ

ស្របតាមគោលការណ៍គន្លឹះ ក្នុងការគ្រប់គ្រងជលផលសមុទ្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ បានកំណត់ចេញ ទស្សនវិស័យ និងគោលការណ៍គន្លឹះសំខាន់ៗ ដូចខាងក្រោម៖

ទស្សនវិស័យ៖ **"ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព ដើម្បីរួមចំណែកដល់ការធានាសន្តិសុខស្បៀង សម្រាប់អនាគតនិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ព្រមទាំងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងភាពចម្រើនរុងរឿងរបស់ប្រទេសជាតិ។"**

ជាពិសេសជលផលខ្នាតតូចមានតួនាទីយ៉ាងសំខាន់ ក្នុងការធានាសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ កាត់បន្ថយភាពក្រីក្រ និងការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។

គោលការណ៍គន្លឹះនៃការគ្រប់គ្រងជលផលសមុទ្រ៖ គោលការណ៍ចម្បងចំនួន៩ សម្រាប់ធានាប្រសិទ្ធភាព និងតម្លាភាពនៃការគ្រប់គ្រងធនធានជលផលសមុទ្រ រួមមាន៖

- ១ | **ការអភិវឌ្ឍប្រកបដោយនិរន្តរភាព**
- ២ | **ការគ្រប់គ្រងជលផលសមុទ្រតាមប្រព័ន្ធអេកូឡូស៊ី**
- ៣ | **អភិបាលកិច្ចល្អ**
- ៤ | **តម្លាភាពនិងការចូលរួម**
- ៥ | **អនុម័តគោលការណ៍អនុវត្តល្អ**
- ៦ | **ការសម្រេចចិត្តផ្អែកលើវិទ្យាសាស្ត្រ**
- ៧ | **រក្សាតុល្យភាពរវាងធនធនធានជលផលនិងសមត្ថភាពនេសាទ**
- ៨ | **ការគ្រង់គ្រងបែបការបន្សាំ និង**
- ៩ | **អភិក្រមប្រុងប្រៀបជាមុន។**



ផែនទីបង្ហាញផ្លូវ សម្រាប់ការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់នេះ នឹងបង្ហាញពីគោលការណ៍គ្រប់គ្រង ចក្ខុវិស័យ និងគោលដៅយុទ្ធសាស្ត្រចម្បងជាគន្លឹះសម្រាប់គ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ប្រកបដោយប្រសិទ្ធភាព។

ការរៀបចំផែនទីបង្ហាញផ្លូវ សម្រាប់គ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ក៏នឹងឆ្លើយតបទៅនឹងក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផលឆ្នាំ២០១៥-២០២៤ (វគ្គទី២) និងរួមចំណែកក្នុងការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០-២០២៤) របស់ខេត្តព្រះសីហនុ ដោយពង្រឹងការថែរក្សានូវកំណើនផលិតផលក្នុងស្រុកសរុបរបស់ខេត្តចំនួន ៧% ការសម្រេចកាត់បន្ថយភាពក្រីក្រក្នុងកម្រិតអត្រាប្រមាណ១% ក្នុងមួយឆ្នាំ ការពង្រឹងសមត្ថភាពនិងអភិបាលកិច្ចក្នុងស្ថាប័នរដ្ឋ ដើម្បីធានាប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើង ព្រមទាំងការលើកកម្ពស់បរិយាកាសធុរកិច្ច និងបរិស្ថានអំណោយផលសម្រាប់ការវិនិយោគ។ **ការពង្រឹងការអនុវត្តនូវគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ និងគោលការណ៍ទាំង៩ ក្នុងការរៀបចំនិងកសាងផែនការអភិវឌ្ឍខេត្ត រួមមាន៖**

- **១** | **ការចែក រំលែកព័ត៌មាន**
- **២** | **តម្លាភាព**
- **៣** | **សង្គតិភាព និងសុខដុមនីយកម្ម**
- **៤** | **ការចូលរួមពិគ្រោះយោបល់ជាទូទៅ**
- **៥** | **ការឆ្លើយតបនឹងតម្រូវការ**
- **៦** | **គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ**
- **៧** | **ប្រសិទ្ធភាព និងសុក្រឹតភាព**
- **៨** | **សេដ្ឋកិច្ច និងសង្គម**
- **៩** | **ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថានការធានាសមធម៌។**



# ៣| ចក្ខុវិស័យតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់



គឺបង្កើតជាតំបន់គ្រប់គ្រង និងការពារធនធានជលផលសមុទ្រ ដើម្បីធានាថាធនធានព្រៃកោងកាង និងជីវៈចម្រុះនានាត្រូវបានថែរក្សា និង អភិរក្ស ដូច្នេះធនធានជលផលសមុទ្រទាំងនោះត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព ដើម្បីគាំទ្រដល់ការចិញ្ចឹមជីវិតរបស់សហគមន៍ តាមរយៈការបង្កើតជាតំបន់អេកូទេសចរណ៍។

**គោលដៅរយៈពេលវែងរបស់តំបន់នេះ** នឹងចូលរួមចំណែកក្នុងការអភិរក្សធនធានតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយប្រសិទ្ធភាព ដើម្បីលើកកម្ពស់ការចិញ្ចឹមជីវិត តាមរយៈការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រដែលមានទំហំផ្ទៃដីសរុប (រួមទាំងផ្ទៃព្រៃ និងផ្ទៃសមុទ្រ) ១០,៩២៣ ហិកតាក្នុងនោះមានព្រៃកោងកាងប្រមាណ ២,៨៧៦ ហិកតា ប្រកបដោយចីរភាពលើធនធាន និងលើកកម្ពស់វិស័យអេកូទេសចរណ៍ ដើម្បីរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់។

# ៤| បញ្ហាប្រឈម

ទន្ទឹមនឹងពង្រឹងការគ្រប់គ្រង និងការការពារដោយយកចិត្តទុកដាក់ពីសំណាក់សមត្ថកិច្ចជំនាញ និងអាជ្ញាធរមូលដ្ឋាន ដើម្បីជំរុញការងារគ្រប់គ្រងតំបន់គ្រប់គ្រងជលផលព្រែកកំពង់ស្មាច់ឱ្យប្រសើរឡើងនោះ ក៏នៅមានបញ្ហាជាច្រើនត្រូវបានរកឃើញក្នុងតំបន់នេះផងដែរ ដែលជះឥទ្ធិពលអវិជ្ជមានដល់ធនធានសមុទ្រ និងជីវៈចម្រុះ សេដ្ឋកិច្ច និងសង្គម។ បញ្ហានោះរួមមាន ការថយចុះនៃព្រៃកោងកាង និងការថយចុះធនធានសមុទ្រជាដើម។ ព្រៃកោងកាងត្រូវបានកាប់ទន្រ្ទានសម្រាប់យកដីធ្វើកម្មសិទ្ធិឯកជននិងការពង្រីកវារីវប្បកម្ម និងការពង្រីកផ្ទៃដីកសិកម្ម ដូចជាការធ្វើស្រែនៅតាមឆ្នេរព្រែក និងផ្នែកខ្លះនៃតំបន់ព្រៃកោងកាង ជាពិសេសផ្នែកកណ្តាលនៃដងព្រែក ការប្រើប្រាស់ជីគីមី និងការខូចខាតកូនកោងកាងតាមរយៈការបំពុល ការហូរច្រោះ និងគ្រោះមហន្តរាយធម្មជាតិជាដើម។ ការធ្លាក់ចុះប្រាក់ចំណូល ការប្រកួតប្រជែងក្នុងការនេសាទ ផលិតផលស្រូវធ្លាក់ចុះ និងចំណេះដឹងប្រជាពលរដ្ឋនៅមានកម្រិតក្នុងការគ្រប់គ្រងសហគមន៍នេសាទ។ ការកង្វះខាតថវិកា សម្រាប់អ្នកពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពនានាក្នុងតំបន់ ក៏ជាបញ្ហាចោទសម្រាប់ការគ្រប់គ្រងតំបន់នេះផងដែរ។



# ៥ | ទិដ្ឋភាពទូទៅនៃផែនទីបង្ហាញផ្លូវ

## គោលបំណង និងការរៀបចំផែនទីបង្ហាញផ្លូវ

ផែនទីបង្ហាញផ្លូវនេះ រៀបចំឡើងសម្រាប់ការគ្រប់គ្រងតំបន់គ្រប់គ្រងធនធានជលផលសមុទ្រព្រែកកំពង់ស្មាច់ ដោយបានឆ្លងកាត់ការប្រជុំពិភាក្សារវាងសហគមន៍នេសាទក្នុងតំបន់ ក្រុមការងារបច្ចេកទេស និងទទួលបានធាតុចូល ព្រមទាំងអនុសាសន៍នានា ពីរដ្ឋបាលជលផល និងអង្គការជាតិ អន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានតំបន់ឆ្នេរ។ ផែនទីបង្ហាញផ្លូវនេះ កំណត់គោលដៅសំខាន់ៗ និងណែនាំលើសកម្មភាពអាទិភាពសំខាន់ៗក្នុងរយៈពេលមធ្យមដល់ថ្នាក់ដឹកនាំ អ្នកគ្រប់គ្រង និងអ្នកប្រតិបត្តិផ្ទាល់ ធ្វើការពិចារណាក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ដើម្បីឈានដល់ការសម្រេចតាមចក្ខុវិស័យតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ និងគោលការណ៍ណែនាំនានារបស់រាជរដ្ឋាភិបាល។



# យុទ្ធសាស្ត្រនៃការអនុវត្តផែនទីបង្ហាញផ្លូវ

ក្រោយពីបានឆ្លងការពិគ្រោះយោបល់ ការផ្តល់ធាតុចូល និងការវិភាគល្អិតល្អន់ ក្រុមការងារបានរៀបចំផែនទីបង្ហាញផ្លូវនេះ ដោយដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចម្បងចំនួន០៥ ដើម្បីឆ្លើយតបនឹងចក្ខុវិស័យរបស់តំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ រួមមានដូចខាងក្រោម៖

## • គោលដៅយុទ្ធសាស្ត្រទី១:

ការពារនិងស្តារមុខងារជីវរូបសាស្ត្រ រួមមានប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងធនធានជលផលសមុទ្រសំខាន់ៗក្នុងតំបន់។

## • គោលដៅយុទ្ធសាស្ត្រទី២:

អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមក្នុងតំបន់ឱ្យមានភាពប្រសើរឡើង។

## • គោលដៅយុទ្ធសាស្ត្រទី៣:

ពង្រឹងអភិបាលកិច្ចតំបន់ប្រកបដោយប្រសិទ្ធភាពខ្ពស់។

## • គោលដៅយុទ្ធសាស្ត្រទី៤:

ផ្តួចផ្តើមបង្កើតនិងអនុវត្តយន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាព និងការចែករំលែកផលប្រយោជន៍ប្រកបដោយតម្លាភាពក្នុងតំបន់។

## • គោលដៅយុទ្ធសាស្ត្រទី៥:

ពង្រឹងភាពធន់ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដោយប្រើសំឡេងវិទ្យាសាស្ត្រ និងការកសាងសមត្ថភាពជាអតិបរមា។

ដ្យាក្រាមទី១៖ គោលដៅយុទ្ធសាស្ត្រចម្បងទាំងប្រាំ



# អ្នកពាក់ព័ន្ធដែលត្រូវការ និងប្រើប្រាស់ផែនទីបង្ហាញផ្លូវ

អ្នកពាក់ព័ន្ធដែលត្រូវការ និងប្រើប្រាស់ផែនទីបង្ហាញផ្លូវផែនទីបង្ហាញផ្លូវនេះ រៀបចំឡើងសម្រាប់រយៈពេលមធ្យម ត្រឹមឆ្នាំ២០២៩ ដោយអនុវត្តតាមគោលដៅយុទ្ធសាស្រ្តចំនួន៥ ហើយគោលដៅនីមួយៗនឹងដាក់ចេញនូវសកម្មភាពអនុវត្តជាក់ស្តែង ដើម្បីតម្រង់ទិស និងបង្ហាញផ្លូវដល់អ្នកគ្រប់គ្រង ក្រុមការងារពាក់ព័ន្ធ និងសហគមន៍នៅក្នុងតំបន់ព្រែកកំពង់ស្នាច់ទាំងអស់ អនុវត្តសកម្មភាពគម្រោងដែលបានដាក់ចេញនេះឱ្យទាន់ពេលវេលា ដើម្បីសម្រេចបាននូវចក្ខុវិស័យ របស់តំបន់នេះ គោលការណ៍គន្លឹះក្នុងការគ្រប់គ្រងជលផលសមុទ្រ និងគោលការណ៍ថ្នាក់ជាតិនានា ក្នុងព្រះរាជាណាចក្រកម្ពុជា។

### ដ្យាក្រាមទី២៖ អ្នកពាក់ព័ន្ធដែលត្រូវការ និងប្រើប្រាស់ផែនទីបង្ហាញផ្លូវ






ក្នុងអំឡុងពេលអនុវត្តន៍ផែនទីបង្ហាញផ្លូវនេះ នឹងមានយន្តការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃពីកម្រិតស្ថាប័នថ្នាក់ខេត្ត ថ្នាក់ជាតិ និងថ្នាក់តំបន់ អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា ក្នុងគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ តាមស្ថានភាពនៃការអនុវត្តគម្រោង។

**គោលដៅយុទ្ធសាស្ត្រទី១ ការពារ និងស្តារមុខងារជីវរូបសាស្ត្រ រួមមានប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងធនធានជលផលសមុទ្រសំខាន់ៗក្នុងតំបន់**

ក្នុងគោលដៅនេះ នឹងលើកកម្ពស់តុល្យាភាពរវាងសុខុមាលភាពអេកូឡូស៊ី ដែលនឹងធ្វើឱ្យធនធានជលផល និងបរិស្ថានមានស្ថេរភាពល្អប្រសើរ ដោយត្រូវអនុវត្តការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងវិស័យ ជលផល និងបានដាក់ចេញនូវសកម្មភាពគម្រោងដល់ឆ្នាំ២០២៩ មានដូចខាងក្រោម៖

១.១. ធ្វើការសិក្សាស្រាវជ្រាវ អំពីប្រភេទសត្វងាយរងគ្រោះ រួមមានផ្សោត អណ្តើកសមុទ្រ សេះសមុទ្រ សត្វល្មូន សត្វពាហនៈ និងសត្វស្លាប ជាដើម ។

១.២. អភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រង និងស្តារឡើងវិញនូវធនធានសំខាន់ដល់មន្ត្រីជំនាញ និងគណកម្មការសហគមន៍នេសាទក្នុងតំបន់ រួមមានការកំណត់ព្រំប្រទល់ និងគ្រប់គ្រងតំបន់អភិរក្ស ការបណ្តុះបណ្តាលជំនាញចាំបាច់សម្រាប់គ្រប់គ្រងដែននេសាទ។

១.៣. បង្កើនការការពារ និងស្តារឡើងវិញនៃប្រភេនធនធានជលផលសំខាន់ៗរួមមានការបង្កើត និងកំណត់តំបន់ជាក់លាក់សម្រាប់តាមដានប្រភេទ ដែលត្រូវការពារ និងស្តារឡើងវិញ ដូចជាព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ និងប្រភេទសត្វព្រៃ និងធនធានជលផលកំពុងរងគ្រោះ (ផ្សោត អណ្តើកសមុទ្រ សេះសមុទ្រ សត្វល្មូន និងសត្វស្លាប ជាដើម)។

១.៤. ការស្តារធនធានសំខាន់ៗជាពិសេសព្រៃកោងកាង តាមរយៈការរៀបចំថ្នាលបណ្តុះកូនកោងកាង ការដាំដុសក្នុងកន្លែងសឹករិចរិល និងការដាំឡើងវិញក្នុងតំបន់ខូចខាត។

១.៥. ធ្វើការវិភាគស្ថានភាពសង្គម និងបរិស្ថាន ដើម្បីកំណត់អត្តសញ្ញាណនៃការទំនាក់ទំនងគ្នា ដូចជាប្រជាជន លំហូរទឹក ប្រព័ន្ធធារាសាស្ត្រ ការធ្វើស្រែកសិកម្ម ការធ្វើវារីវប្បកម្ម ការហូរច្រោះ ... ដែលអាចរារាំងនូវការគ្រប់គ្រង និងអភិរក្សព្រៃកោងកាងនៅក្នុងតំបន់។ ត្រូវធ្វើការដោះស្រាយបញ្ហាប្រឈមនេះ ជាអន្តរវិស័យ និងចាត់អាទិភាពផ្សេងគ្នា ដោយធ្វើការពិគ្រោះយោបល់ដែលមានលក្ខណៈគ្រប់គ្រងជ្រុងជ្រោយ។

១.៦. ពង្រឹងសមត្ថភាពមន្ត្រីជំនាញ និងគណកម្មការសហគមន៍នេសាទក្នុងការគ្រប់គ្រង និងការប្រើប្រាស់ឧបករណ៍នេសាទក្នុងតំបន់ រួមមានការកំណត់ប្រភេទ និងចំនួនឧបករណ៍នេសាទដែរត្រូវអនុញ្ញាត និងកំណត់ការបិទនេសាទនារដូវពងកូន ជាពិសេសត្រីកាម៉ុង ក្តាមសេះពងកូនជាដើម។

១.៧. ពង្រឹងការការពារ និងស្តារមុខងារសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះសមុទ្រនៅក្នុងតំបន់ រួមមានការកំណត់ និងគ្រប់គ្រងតំបន់អភិរក្សធនធានសមុទ្រ (ក្តាមថ្ម និងគ្រែងឈាម)។

១.៨. បង្កើនប្រសិទ្ធភាពស្តារប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង ដោយសហគមន៍នេសាទក្នុងតំបន់តាមរយៈការផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសសមស្រប "ការស្តារព្រៃកោងកាងតាមសហគមន៍ Community-based Ecological Mangrove Restoration (CBEMR)" ដល់គណៈកម្មការសហគមន៍នេសាទ និងមន្ត្រីជំនាញ។

១.៣. បង្កើនចំណេះដឹង ស្តីពីតំលៃ និងសារៈសំខាន់ធនធានជលផលសមុទ្រ រួមមានព្រៃកោងកាង ស្មៅសមុទ្រ និងប្រភេទសត្វព្រៃ និងធនធានជលផលកំពុងរងគ្រោះថ្នាក់ ដល់សហគមន៍មូលដ្ឋាន រួមទាំងអាជ្ញាធរមូលដ្ឋាន និងវិស័យឯកជនក្នុងតំបន់។

## តារាងទី១៖

សកម្មភាពគោលដៅយុទ្ធសាស្រ្តទី១ - ការពារ និង ស្តារមុខងារជីវរូបសាស្រ្ត

| សកម្មភាព | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ |
|---|---|---|---|---|---|---|---|---|
| ស. ១.១ | | | | | | | | |
| ស. ១.២ | | | | | | | | |
| ស. ១.៣ | | | | | | | | |
| ស. ១.៤ | | | | | | | | |
| ស. ១.៥ | | | | | | | | |
| ស. ១.៦ | | | | | | | | |
| ស. ១.៧ | | | | | | | | |
| ស. ១.៨ | | | | | | | | |
| ស. ១.៩ | | | | | | | | |

## គោលដៅយុទ្ធសាស្ត្រទី២ អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមក្នុងតំបន់ឱ្យមានភាពប្រសើរឡើង

ការអភិរក្សជីវចម្រុះសមុទ្រ តាមរយៈតំបន់គ្រប់គ្រងជលផលសមុទ្រ គួរតែត្រូវបានរួមបញ្ចូលនូវសកម្មភាពគម្រោងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់សហគមន៍នេសាទ។ ប្រសិទ្ធភាពនៃតំបន់គ្រប់គ្រងជលផលសមុទ្រ ទាមទារឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសសហគមន៍ក្នុងមូលដ្ឋាន ចូលរួមក្នុងការរៀបចំផែនការ ការធ្វើផែនទី ការអនុវត្ត និងការត្រួតពិនិត្យតំបន់គ្រប់គ្រងជលផលសមុទ្រ។ ដូចគ្នានេះដែរ អ្នកនេសាទ និងសហគមន៍ទាំងអស់នៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រ គួរទទួលបាននូវការចែករំលែកអត្ថប្រយោជន៍។ ព្រៃកោងកាង ផ្តល់អត្ថប្រយោជន៍សង្គម-សេដ្ឋកិច្ចសំខាន់ៗ ដល់សហគមន៍ មូលដ្ឋាននៅទូទាំងពិភពលោក។ ដូច្នេះ វាចាំបាច់ណាស់ក្នុងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី ព្រៃកោងកាង និងធនធានជលផល និងផ្ទៃដី ប្រកបដោយនិរន្តរភាព ដើម្បីរក្សានិងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍។ គោលដៅយុទ្ធសាស្ត្រនេះ នឹងដាក់ចេញសកម្មភាពអាទិភាពមានដូចខាងក្រោម៖

២.១. ធ្វើការសិក្សាអំពីតម្រូវគម្រោងចិញ្ចឹមជីវិត និងចង្វាក់ទីផ្សារផលិតផល សម្រាប់សហគមន៍នៅក្នុងតំបន់ព្រៃកកំពង់ស្នាច់ ដើម្បីណែនាំអំពីមុខរបរ និងការបណ្តុះបណ្តាញជំនាញ។

២.២. ធ្វើការសិក្សាអំពីតម្រូវការបណ្តុះបណ្តាលមុខរបរនិងជំនាញទន់ លើគម្រោងជីវិតរបស់សហគមន៍ ដើម្បីពួកគាត់អាចពង្រឹង និងកសាងជីវភាពរស់ប្រសើរជាងមុន និងមិនកាប់ទន្ទ្រានព្រៃកោងកាងដើម្បីរកប្រាក់ចំណូល។

២.៣. សម្របសម្រួល ទំនាក់ទំនង និងស្វែងរកទីផ្សារផលិតរបស់សហគមន៍ដែលគាត់ផលិតបាន។

២.៤. បង្កើនសន្តិសុខស្បៀង និងអាហាររូបត្ថម្ភ ដល់ប្រជាពលរដ្ឋមូលដ្ឋាន ជាពិសេសអ្នកក្រីក្រ ដែរពឹងផ្អែកលើធនធានជលផល តាមរយៈការជម្រុញការនេសាទស្របច្បាប់លក្ខណៈគ្រួសារ និងបង្កើតជម្រើសមុខរបរបន្ថែម រួមមានវារីវប្បកម្ម ការកែច្នៃផលនេសាទ និងពង្រឹងទីផ្សារជលផល។

២.៥. បង្កើតតំបន់អេកូទេសចរណ៍ (Eco-Tourism) ក្នុងសហគមន៍នេសាទដែលមានសក្តានុពលសម្រាប់ជាប្រភពហិរញ្ញវត្ថុគាំទ្រដល់ជីវភាពគណៈកម្មការសហគមន៍នេសាទ និងសមាជិកសហគមន៍ ព្រមទាំងរួមចំណែកដល់សកម្មភាពអភិរក្សស្នូលដោយសហគមន៍។

២.៦. បង្កើតយន្តការបែងចែកផលប្រយោជន៍ពីតំបន់គ្រប់គ្រងជលផលប្រកបដោយសមធម៌ តាមរយៈការគាំទ្រដល់គ្រួសារក្រីក្រ ឱ្យមានឱកាសទទួលបានប្រាក់ចំណូល និងអត្ថប្រយោជន៍នានាដោយតម្លាភាពនិងសមធម៌។

២.៧. ជម្រុញ និងលើកទឹកចិត្តអ្នកនេសាទខ្នាតតូច អ្នកក្រីក្រ និងស្ត្រីក្នុងមូលដ្ឋានចូលរួមជាគណៈកម្មការសហគមន៍នេសាទ និងសកម្មភាពរកប្រាក់ចំណូល ជាពិសេសពង្រឹងសមត្ថភាពក្នុងគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចចិត្តដើម្បីផលប្រយោជន៍សហគមន៍។

២.៨. បង្កើនការយល់ដឹង និងការចូលរួមអនុវត្តច្បាប់ស្តីពីជលផល បទបញ្ញាតិនានា រួមទាំងគោលការណ៍ណែនាំដល់សហគមន៍មូលដ្ឋាន អាជ្ញាធរ ប្រតិបត្តិករទេសចរណ៍ សម្រាប់ធានាបានការគ្រប់គ្រងតំបន់ប្រកបដោយប្រសិទ្ធភាព តាមរយៈការបណ្តុះបណ្តាលគ្រូបង្គោល និងផ្សព្វផ្សាយសារធារណៈ។

២.៩. លើកកម្ពស់ការយល់ដឹង និងចូលរួមការគ្រប់គ្រងបរិស្ថានក្នុងតំបន់ រួមមានការគ្រប់គ្រងសំណល់រឹង-រាវ ដោយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន តាមរយៈវិធីសាស្ត្រ ៣Rs និងយុទ្ធនាការអប់រំ និងការពិន័យ។

២.១០. ផ្សារភ្ជាប់ និងពង្រឹងទំនាក់ទំនងល្អក្នុងសង្គម និងវប្បធម៌ រួមមានការនេសាទបែបប្រពៃណី ការរៀបចំព្រឹត្តិការណ៍កម្សាន្តសហគមន៍ កម្មវិធីបុណ្យជំនឿសាសនា និងការគោរពគ្នាឱ្យកាន់តែទូលំទូលាយ។

២.១១. កៀរគរសមាជិកសហគមន៍ រៀបចំព្រឹត្តិការណ៍ធំៗសម្រាប់សហគមន៍ ដូចជា រុក្ខាទិវា (ដាំកោងកាង) ទិវាសមុទ្រ និងទិវាសំអាតសហគមន៍ ជាដើម។

២.១២. ធ្វើការផ្សព្វផ្សាយអំពី តំបន់គ្រប់គ្រងជលផលសមុទ្រ ព្រែកកំពង់ស្នាច់ តាមបណ្តាញសង្គម និងទូរទស្សន៍ ដើម្បីទាក់ ទាញទេសចរណ៍ សិស្សនិស្សិត មកសម្រាកកំសាន្ត និងសិក្សាស្រាវជ្រាវ។

## តារាងទី២៖

សកម្មភាពគោលដៅយុទ្ធសាស្ត្រទី២ - **អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម**

| សកម្មភាព | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ |
|---|---|---|---|---|---|---|---|---|
| ស. ២.១ | ■ | ■ | | | | | | |
| ស. ២.២ | | ■ | ■ | | | | | |
| ស. ២.៣ | | | ■ | | | | | |
| ស. ២.៤ | | | ■ | ■ | | | | |
| ស. ២.៥ | | | ■ | ■ | ■ | | | |
| ស. ២.៦ | | | | | ■ | ■ | ■ | ■ |
| ស. ២.៧ | | | | | ■ | ■ | ■ | ■ |
| ស. ២.៨ | | | | ■ | ■ | ■ | ■ | ■ |
| ស. ២.១០ | | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ស. ២.១១ | | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ស. ២.១២ | | ■ | ■ | ■ | ■ | ■ | ■ | ■ |

## គោលដៅយុទ្ធសាស្ត្រទី៣ ពង្រឹងអភិបាលកិច្ចតំបន់ប្រកបដោយប្រសិទ្ធភាពខ្ពស់

ទាមទារឱ្យមានការគាំទ្រពីគោលនយោបាយ និងក្របខណ្ឌច្បាប់ថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីផ្តល់ការណែនាំជារួមសម្រាប់ការអភិរក្ស និងការប្រើប្រាស់ធនធានព្រៃកោងកាងប្រកបដោយនិរន្តរភាព និងធានាបាននូវការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ សម្រាប់រយៈពេលវែង។ ដើម្បីសម្រេចបាននូវកិច្ចការនេះ គោលនយោបាយ និងច្បាប់ចាំបាច់ត្រូវតែជំរុញការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងប្រកបដោយនិរន្តរភាព ទន្ទឹមនេះ ក៏ត្រូវការដោះស្រាយនូវបញ្ហាគំរាមកំហែង និងកត្តាធ្វើឱ្យបាត់បង់ និងការរិចរិលព្រៃកោងកាងផងដែរ។ ការគ្រប់គ្រងរួមគ្នា (Co-Management) គឺជាគន្លឹះនៃការគ្រប់គ្រងជោគជ័យរបស់តំបន់គ្រប់គ្រងជលផលសមុទ្រនេះ។ គោលដៅនេះ ដាក់ចេញនូវសកម្មភាពអាទិភាពដល់ឆ្នាំ២០២៩ ដូចខាងក្រោម៖

៣.១. ធ្វើបច្ចុប្បន្នភាពក្រុមប្រឹក្សាភិបាលគ្រប់គ្រង និងក្រុមការងារបច្ចេកទេស ដើម្បីធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់ប្រកដដោយប្រសិទ្ធភាពខ្ពស់។

៣.២. ធ្វើបច្ចុប្បនភាពផែនការគ្រប់គ្រងតំបន់ ដោយរួមបញ្ចូលផែនការគ្រប់គ្រង និងផែនការវិនិយោគសហគមន៍នេសាទ ដើម្បីធានាការអនុវត្តបានគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពខ្ពស់។

៣.៣. ពង្រឹងសមត្ថភាពធនធានមនុស្ស រួមមានសមាជិកក្រុមការងារបច្ចេកទេស មន្ត្រីជំនាញ និងគណៈកម្មការសហគមន៍ ដើម្បីមានជំនាញគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវចាំបាច់ក្នុងការប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។

៣.៤. ពង្រឹងប្រសិទ្ធភាពប្រព័ន្ធអនុវត្តច្បាប់ តាមរយៈការផ្សព្វផ្សាយច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធដល់សហគមន៍ និងអ្នកប្រើប្រាស់ធនធាន ជាពិសេសការអនុវត្តការល្បាតតាមកម្មវិធីស្មាត "SMART" ដល់មន្ត្រីជំនាញ និងគណៈកម្មការសហគមន៍នេសាទក្នុងតំបន់ ដើម្បីការពារធនធានជលផលជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីសមុទ្រពីសកម្មភាពខុសច្បាប់នានា។

៣.៥. ធ្វើការសិក្សាអំពីតម្រូវការឧបករណ៍បច្ចេកវិទ្យាសម្រាប់ប្រើប្រាស់ និងគ្រប់គ្រងក្នុង តំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់ ដូចជា ទូកល្បាតលឿន ម៉ូតូល្បាត ប៉មសុវត្ថិភាព វ៉ាជាមើលសត្វ ឧបករណ៍តាមដានសត្វស្លាប និងជីវៈចម្រុះ ប៉មកំណត់កន្លែងអភិរក្ស និងកន្លែងគ្រប់គ្រង បង្គោលព្រំ ឧបករណ៍វិភាគ និងតាមដានគុណភាពព្រៃកោងកាង និង GIS ជាដើម... ដែលអ្នកគ្រប់គ្រងតំបន់ត្រូវការសម្រាប់ការបំពេញការងារប្រកបដោយប្រសិទ្ធភាព។

៣.៦. ពង្រឹងប្រសិទ្ធភាពអភិបាលកិច្ចតំបន់គ្រប់គ្រង ដោយប្រើប្រាស់ឧបករណ៍វាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រង (METT) និងកំណត់អាទិភាពសកម្មភាពសម្រាប់ទិសដៅបន្ត។

៣.៧. រៀបចំកិច្ចប្រជុំតាមដានវឌ្ឍនភាពក្រុមល្បាត គណៈកម្មការសហគមន៍ ក្រុមការងារបច្ចេកទេសជាទៀងទាត់ ដើម្បីទទួលបាននូវវឌ្ឍនភាពការងារដោះស្រាយការប្រឈមនៅនឹងតំបន់ និងស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុគាំទ្រឆ្លើយតប។

៣.៨. ការតាមដាននូវស្ថានភាពប្រែប្រួលទាំងឡាយពាក់ព័ន្ធនឹង ស្ថានភាពព្រៃកោងកាង ជីវៈជម្រុះ ព្រំប្រទល់ បរិស្ថាន និងគ្រោះមហន្តរាយផ្សេងៗ ដើម្បីធ្វើសេចក្តីរាយការណ៍ និងដោះស្រាយបន្ទាន់។

៣.៩. លើកទឹកចិត្ត និងពង្រឹងការរៀនសូត្រអំពីការថែរក្សាព្រៃកោងកាង និងជីវៈចម្រុះតំបន់ឆ្នេរ ព្រមទាំងយន្តការនៃការអនុវត្តច្បាប់នានា ជាមួយ អង្គការសង្គមស៊ីវិលនានាដើម្បីបង្កើនសមត្ថភាព។

៣.១០. ពង្រឹងយន្តការគ្រប់គ្រងដែលមានស្រាប់ ដោយលើកកម្ពស់អភិបាលកិច្ចល្អ ដើម្បីបញ្ឈប់ការបាត់បងជីវៈចម្រុះ និងថែរក្សាមុខងារ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី តាមរយៈការអនុវត្តឡោមតាមច្បាប់ជលផល លិខិតបទដ្ឋាន គតិយុត្តនានាពាក់ព័ន្ធនានា ដែលចេញដោយមន្ទីរជំនាញ រដ្ឋបាលស្រុក ខេត្ត និងថ្នាក់ជាតិ។

៣.១១. ពង្រឹងកិច្ចសហប្រតិបត្តិការវាងថ្នាក់ជាតិ ថ្នាក់ខេត្ត សហគមន៍មូលដ្ឋាន តាមរយៈការបង្កើត និងពង្រឹងក្រុមការងារសហគ្រប់គ្រង ដោយរួមបញ្ចូលពីគ្រប់ភាគីពាក់ព័ន្ធសំខាន់ៗ រួមមានរដ្ឋាភិបាល សហគមន៍មូលដ្ឋាន និងក្រុមហ៊ុនឯកជន ជាពិសេសក្នុងការធ្វើផែនការ អនុវត្ត និងគ្រប់គ្រងធនធានក្នុងតំបន់។

៣.១២. ជំរុញការរៀបចំដាក់ចូលជាសមាជិកបណ្តាញតំបន់ការពារសមុទ្រ (MPA Network) ក្នុងប្រទេស តំបន់អាស៊ី និងសកលលោក ដើម្បីទទួលបានធាតុចូលពីការអភិវឌ្ឍតំបន់ ការចែករំលែកបទពិសោធន៍ និងផ្សព្វផ្សាយតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្នាច់។

## តារាងទី៣៖

សកម្មភាពគោលដៅយុទ្ធសាស្ត្រទី៣ - ពង្រឹងអភិបាលកិច្ច

| សកម្មភាព | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ |
|---|---|---|---|---|---|---|---|---|
| ស. ៣.១ | | | | | | | | |
| ស. ៣.២ | | | | | | | | |
| ស. ៣.៣ | | | | | | | | |
| ស. ៣.៤ | | | | | | | | |
| ស. ៣.៥ | | | | | | | | |
| ស. ៣.៦ | | | | | | | | |
| ស. ៣.៧ | | | | | | | | |
| ស. ៣.៨ | | | | | | | | |
| ស. ៣.១០ | | | | | | | | |
| ស. ៣.១១ | | | | | | | | |
| ស. ៣.១២ | | | | | | | | |

## គោលដៅយុទ្ធសាស្រ្តទី៤ ផ្តួចផ្តើមបង្កើត និងអនុវត្តយន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាព និងការចែករំលែកផលប្រយោជន៍ប្រកបដោយតម្លាភាពក្នុងតំបន់

ខណៈដែលការអភិរក្សព្រៃកោងកាងទាមទារការថែទាំរយៈពេលវែង ដូច្នេះការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានទាក់ទងនឹងអត្ថប្រយោជន៍សេដ្ឋកិច្ចទាំងរយៈពេលខ្លី និងរយៈពេលវែង ដើម្បីទទួលបានពីការស្តារ និងអភិរក្សព្រៃកោងកាង គួរតែត្រូវបានដោះស្រាយជូនគាត់។ អ្នកគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រ ត្រូវប្រាកដថា សកម្មភាពសេដ្ឋកិច្ចណាមួយ (ឧ. អេកូទេសចរណ៍ ការរៀបចំវារីវប្បកម្មចម្រុះ) ដែលធ្វើឡើងនៅក្នុង និងជុំវិញព្រៃកោងកាងអនុវត្តតាមគ្រោងការណ៍ប្រើប្រាស់ប្រកបដោយនិរន្តរភាព និងជាក់លាក់ក្នុងមូលដ្ឋាន ជៀសវាងការកែប្រែ និងទប់ស្កាត់ការរិចរិលនៃប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង និងធានាអត្ថប្រយោជន៍ដល់ការអភិរក្សបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ខណៈដែលជៀសវាងផលប៉ះពាល់អវិជ្ជមានលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីផ្សេងទៀត។ ក្នុងគោលដៅនេះ បានដាក់ចេញនូវសកម្មភាពដូចខាងក្រោម៖

៤.១. ផ្តួចផ្តើមបង្កើតក្រុមការងារស្នូល សម្រាប់បង្កើតយន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាពសម្រាប់តំបន់គ្រប់គ្រងជលផលសមុទ្រស្របតាមក្របខណ្ឌច្បាប់ ដូចជាភាពជាដៃគូ រវាងសាធារណៈ-ឯកជន ទំនួលខុសត្រូវរបស់វិស័យឯកជន មូលនិធិអភិរក្សសហគមន៍ និងសកម្មភាពបង្កើតប្រាក់ចំណូលពីធម្មជាតិ ឬគំនិតហិរញ្ញវត្ថុផ្សេងៗ និងឱកាសថ្មីពីការកិច្ចខិតខំប្រឹងប្រែងអភិរក្សព្រៃកោងកាងជាដើម សិក្សានិងវាយតម្លៃពីជម្រើសសមស្រប ក្នុងការបង្កើតតំបន់អេកូទេសចរណ៍ ព្រមទាំងធ្វើការពិភាក្សានិងឯកភាពលើប្លង់មេនៃគម្រោងសកម្មភាពអេកូទេសចរណ៍។

៤.២. រៀបចំយន្តការបែងចែកផលប្រយោជន៍ប្រកបដោយតម្លាភាពសម្រាប់គ្រប់គ្រងតំបន់ និងការផ្តល់មូលនិធិដោយផ្ទាល់ទៅឱ្យសហគមន៍នេសាទ ផ្តោតទៅលើឱកាសផ្លូវច្បាប់ ការអនុត្តជាក់ស្តែងសង្គមវប្បធម៌។

៤.៣. បង្កើនការខំប្រឹងប្រែងដើម្បីកសាងសមត្ថភាព និងការបង្កើតការងារសម្រាប់សហគមន៍ដែលពឹងផ្អែកលើធនធានធម្មជាតិព្រៃកោងកាង ដែលរស់នៅជាប់នឹងតំបន់អភិរក្សព្រៃកោងកាង ការបញ្ចូលជីវភាពរស់នៅ និងការបង្កើតការងារក្រោមគោលនយោបាយនៃការអភិវឌ្ឍជាតិ។

៤.៤. រៀបចំផែនការគៀងគរមូលនិធិសម្រាប់បង្កើតយន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាពសម្រាប់តំបន់គ្រប់គ្រងជលផលសមុទ្ររយៈពេលខ្លី មធ្យម និងវែង។

៤.៥. ស្វែងរកការគាំទ្រ និងជម្រុញការអនុវត្តសាកល្បងបង្កើតយន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាពនិងយន្តការបែងចែកផលប្រយោជន៍ប្រកបដោយតម្លាភាព សម្រាប់តំបន់គ្រប់គ្រងជលផលសមុទ្ររយៈពេលខ្លី។

៤.៦. អនុវត្តយន្តការនិរន្តរភាពហិរញ្ញប្បទានរយៈពេលមធ្យម និងវែង។

## តារាងទី៤៖

**សកម្មភាពគោលដៅយុទ្ធសាស្ត្រទី៤ - យន្តការផ្តល់ហិរញ្ញប្បទានប្រកបដោយនិរន្តរភាពនិង ការចែករំលែកផលប្រយោជន៍**

| សកម្មភាព | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ |
|---|---|---|---|---|---|---|---|---|
| ស. ៤.១ | | | | | | | | |
| ស. ៤.២ | | | | | | | | |
| ស. ៤.៣ | | | | | | | | |
| ស. ៤.៤ | | | | | | | | |
| ស. ៤.៥ | | | | | | | | |
| ស. ៤.៦ | | | | | | | | |

## គោលដៅយុទ្ធសាស្ត្រទី៥ ពង្រឹងភាពធន់ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុដោយប្រើសំឡេងវិទ្យាសាស្ត្រ និងការកសាងសមត្ថភាពជាអតិបរមា

ការសិក្សាអំពីស្ថានភាពជីវសាស្ត្រក្នុងតំបន់ និងភាពងាយរងគ្រោះនៃព្រៃកោងកាង ការធ្វើផែនទីបញ្ជីសារពើភណ្ឌ ការត្រួតពិនិត្យទិន្នន័យ និងការវាយតម្លៃសេដ្ឋកិច្ច គួរតែត្រូវបានរៀបចំឡើង ដើម្បីគាំទ្រដល់ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង និងតំបន់ព្រែកកំពង់ស្នាច់ ប្រកបដោយនិរន្តរភាព។ ការសិក្សានេះ នឹងផ្តល់នូវមូលដ្ឋានសម្រាប់ជាភស្តុតាង និងរបរគំហើញដ៏សមស្រប ដើម្បីបង្ហាញនូវតម្រូវការការកសាងសមត្ថភាពនៃផ្នែកការងារទាំងនោះផងដែរ។ គោលដៅយុទ្ធសាស្ត្រនេះ បានដាក់ចេញនូវសកម្មភាពអាទិភាពដូចខាងក្រោម៖

**៥.១.** សិក្សាវាយតម្លៃអំពីភាពងាយរងគ្រោះ និងហានិភ័យក្នុងតំបន់ ដើម្បីចាត់វិធានការអាទិភាពសម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ រួមមានការកើនឡើងកំពស់ទឹកសមុទ្រ ការហូរច្រោះ ការជ្រាបទឹកប្រៃចូលក្នុងដីស្រែ។

**៥.២.** បង្កើត និងរក្សាសារពើភ័ណ្ឌព្រៃកោងកាង ដើម្បីប្រមូល គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យ ព្រៃកោងកាងដែលមានស្រាប់ និងធានាផ្សេងៗទៀត ឱ្យមានព័ត៌មានវិទ្យាសាស្ត្រ សម្រាប់អ្នកគ្រប់គ្រង អ្នករៀបចំគោលនយោបាយ និងអ្នកស្រាវជ្រាវ។

**៥.៣.** ធ្វើការសិក្សាអំពីសុខភាពព្រៃកោងកាង (Mangrove Health Monitoring) ដែលវានឹងផ្តល់របាយការណ៍ទៀងទាត់អំពីស្ថានភាពសុខភាពព្រៃកោងកាង (វិសាលភាព ភាពសម្បូរបែបនៃ ជីវៈចម្រុះគ្រប់ប្រភេទ ការចែកចាយ ស្ថានភាពគ្រប់គ្រងការអភិរក្ស។ល។)។ ពិចារណាលើលទ្ធផលដែលបានសិក្សា និងសេណារីយ៉ូលើការអភិវឌ្ឍនាពេលអនាគត ដែលជះឥទ្ធិពលដល់ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង ដូចជាផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ការព្យាករណ៍ (ឧ. ការកើនឡើងនីវ៉ូទឹកសមុទ្រ) ឬការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រ ដែលអាចនាំឱ្យមានការលិចលង់នៅតំបន់ឆ្នេរសមុទ្រ។

**៥.៤.** ធ្វើការវិភាគតម្លៃសេដ្ឋកិច្ច និងភាពធន់នៃព្រៃកោងកាង ដែលឆ្លើយតបដល់សេដ្ឋកិច្ចជាតិ ដើម្បីបង្កើនការយល់ដឹងអំពីតម្លៃប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង សម្រាប់ការថែរក្សាជីវចម្រុះ និងជីវភាពរស់នៅ ការធានាបានសន្តិសុខស្បៀង ការការពារទ្រព្យសម្បត្តិ ដូចជាហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេរជាដើម។

**៥.៥.** ធ្វើការសិក្សារៀបចំគម្រោងពាក់ព័ន្ធនឹងវិធីសាស្ត្រផ្អែកលើធម្មជាតិសម្រាប់ការកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ (Natural-Based Approaches for Climate Change Mitigation and Adaptation)។

**៥.៦.** ពង្រឹងការអភិរក្សជីវៈចម្រុះ និងស្តារប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរសមុទ្រ ដែលរងការគម្រាមកំហែងពីការប្រែប្រួលអាកាសធាតុ រួមមានព្រៃកោងកាង ស្មៅសមុទ្រ និងផ្កាថ្ម។

**៥.៧.** លើកកម្ពស់វិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុថ្នាក់សហគមន៍ ជាពិសេសផ្តល់អាទិភាពដល់តម្រូវការស្ត្រី និងអ្នកក្រីក្រ និងពង្រឹងភាពជាដៃគូរវាងស្ថាប័នពាក់ព័ន្ធនៅក្នុងតំបន់ ឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង។

**៥.៨.** ពង្រឹងភាពធន់នឹងអាកាសធាតុ តាមរយៈជម្រើសមុខរបរសមស្របដើម្បីធានាសន្តិសុខស្បៀង ទឹក និងថាមពលដល់សហគមន៍ ជាពិសេសផ្តល់អាទិភាពដល់ស្ត្រី និងអ្នកក្រីក្រ។

**៥.៨.** លើកកម្ពស់ប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈយន្តការសមស្រប រួមមានយន្តការផ្អែកលើសហគមន៍ យន្តការផ្អែកលើអេកូឡូស៊ី និងទេសចរណ៍ធម្មជាតិ។

**៥.១០.** លើកកម្ពស់ការប្រើប្រាស់យន្តការការបង់ថ្លៃសេវាប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរសមុទ្រ រួមទាំងកម្មវិធីកាត់បន្ថយឧស្ម័នពីការបាត់បង់ និងការរេចរិលព្រៃឈើ (REDD+) និងកាបូនខៀវ (Blue Carbon)។

**៥.១១.** ធ្វើការជាមួយស្ថាប័នសិក្សា និងអង្គការដៃគូអភិវឌ្ឍន៍នានា ដើម្បីធានាថា អ្នករៀបចំគោលនយោបាយ រាជរដ្ឋាភិបាល និងសាធារណៈជនអាចទទួលបានព័ត៌មានវិទ្យាសាស្ត្រដែលអាចទុកចិត្ត និងអាចយល់បានកាន់តែច្រើនអំពីព្រៃកោងកាង។ គួរមានការរៀបចំការវេទិកាពិភាក្សាស្តីពី វិទ្យាសាស្ត្រ និងគោលនយោបាយ ដើម្បីធានាបាននូវការផ្ទេរចំណេះដឹងប្រកបដោយប្រសិទ្ធភាព។

## តារាងទី៥៖

**សកម្មភាពគោលដៅយុទ្ធសាស្ត្រទី៤ -ពង្រឹងភាពធន់ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ**

| សកម្មភាព | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | ២០២៨ | ២០២៩ |
|---|---|---|---|---|---|---|---|---|
| ស. ៥.១ | | | | | | | | |
| ស. ៥.២ | | | | | | | | |
| ស. ៥.៣ | | | | | | | | |
| ស. ៥.៤ | | | | | | | | |
| ស. ៥.៥ | | | | | | | | |
| ស. ៥.៦ | | | | | | | | |
| ស. ៥.៧ | | | | | | | | |
| ស. ៥.៨ | | | | | | | | |
| ស. ៥.១០ | | | | | | | | |
| ស. ៥.១១ | | | | | | | | |

# ៦ | យន្តការអនុវត្ត និងហិរញ្ញវត្ថុ



## ៦.១. យន្តការនៃការគ្រប់គ្រង

រដ្ឋបាលខេត្តព្រះសីហនុ បានផ្តួចផ្តើមរៀបចំបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ នៅឆ្នាំ២០១១ តាមរយៈការសិក្សាស្រាវជ្រាវបឋម និងចាប់ផ្តើមដំណើរការពិគ្រោះយោបល់។ នៅឆ្នាំ២០១៤ រដ្ឋបាលខេត្តព្រះសីហនុ បានទទួលបានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការធ្វើការសិក្សា តាមរយៈលិខិតលេខ ៣៦៧៩ កសក ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៤។
ការសម្រេចចិត្ត ស្តីពីការកំណត់គោលដៅ គោលបំណង ការគ្រប់គ្រង និងការកំណត់កន្លែងគ្រប់គ្រង សម្រាប់តំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ត្រូវធ្វើឡើងតាំងពីឆ្នាំ២០១៧-២០១៨ មកម្ល៉េះ។ នៅឆ្នាំ២០១៩ រដ្ឋបាលខេត្តព្រះសីហនុ បានបង្កើតក្រុមការងារបច្ចេកទេស សម្រាប់គ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ដែលដឹកនាំដោយលោក គង់ វិតាណៈ អភិបាលរងខេត្ត ជាអ្នកដឹកនាំរួម ដោយមានការចូលរួមពីតំណាងមន្ទីរពាក់ព័ន្ធសំខាន់ៗក្នុងខេត្ត អាជ្ញាធរមូលដ្ឋាន សហគមន៍ និងអង្គការដៃគូនានា ។




ក្រុមការងារបានចាប់ផ្តើមនូវដំណើរការការងារនេះ ដោយមានការពិគ្រោះយោបល់ថ្នាក់មូលដ្ឋាន ការចងក្រងឯកសារ និងការដាក់បញ្ចូលនូវទិន្នន័យជីវសាស្ត្រ និងការប្រជុំឆ្លងថ្នាក់ដឹកនាំខេត្ត និងគណៈអភិបាលខេត្តព្រះសីហនុ។ ផែនទីកំណត់កន្លែងគ្រប់គ្រង និងកន្លែងប្រើប្រាស់ ត្រូវបានរៀបចំឡើងតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ និងការគាំទ្របច្ចេកទេសពីរដ្ឋបាលជលផល។ រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ជាស្ថាប័នប្រឹក្សាយោបល់ ស្តីពីយុទ្ធសាស្ត្រ គោលការណ៍ណែនាំ គោលនយោបាយ និងផែនការនានា ដល់ការអនុវត្តតំបន់គ្រប់គ្រងជលផលសមុទ្រ។

## ដ្យាក្រាមទី៣៖

រចនាសម្ព័ន្ធគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់



## ៦.២. ប្រភពហិរញ្ញវត្ថុ

ហិរញ្ញវត្ថុប្រើប្រាស់សម្រាប់ទ្រទ្រង់ដល់ដំណើរការអនុវត្ត ផែនទីបង្ហាញផ្លូវនេះ នឹងត្រូវប្រើប្រាស់ប្រភពហិញ្ញវត្ថុពីមន្ទីរវិស័យ រដ្ឋបាលស្រុក និងឃុំសង្កាត់របស់រដ្ឋបាលខេត្តព្រះសីហនុ និងប្រភពហិរញ្ញវត្ថុពីបណ្តាដៃគូអភិវឌ្ឍន៍នានា លើការការពារ និងស្តារឡើងវិញនូវធនធានជលផល និងជីវៈចម្រុះ។

ក្រុមការងារបច្ចេកទេស មន្ទីរវិស័យពាក់ព័ន្ធ និងរដ្ឋបាលមូលដ្ឋាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការកៀរគរប្រភពហិរញ្ញវត្ថុ ដើម្បីទ្រទ្រង់ដល់ការគ្រប់គ្រង និងដំណើរការអនុវត្តតំបន់គ្រប់គ្រងធនធានជលផលសមុទ្រព្រែកកំពង់ស្នាច់។



## ៦.៣. ការតាមដាន និងវាយតំលៃ

ឧបករណ៍ និងវិធីសាស្រ្តដូចខាងក្រោមនេះ ក្រុមការងារបច្ចេកទេសតំបន់គ្រប់គ្រងធនធានជលផលសមុទ្រព្រែកកំពង់ស្នាច់ នឹងជ្រើសរើស និងប្រើប្រាស់សម្រាប់ធ្វើការតាមដាន និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តតំបន់គ្រប់គ្រងធនធានជលផលសមុទ្រនេះ ព្រមទាំងឧបករណ៍ផ្សេងៗទៀតតាមការចាំបាច់។

### • ការតាមដានប្រសិទ្ធភាពតាមរយៈវិធាន METT:

វិធាន METT គឺជាវិធានមួយដែលត្រូវបានអភិវឌ្ឍន៍ពីវិធានរបស់ សម្ព័ន្ធភាពរវាង ធនាគារពិភពលោក និងមូលនិធិពិភពលោកសម្រាប់ធម្មជាតិ សម្រាប់តំបន់ការពារជាក់លាក់ណាមួយ ក្នុងគោលបំណងជួយដល់អ្នកគ្រប់គ្រង និងអ្នកពាក់ព័ន្ធនានាកំណត់នូវវិវឌ្ឍនភាពក្នុងការគ្រប់គ្រងរបស់ពួកគេ ។ និងអ្នកពាក់ព័ន្ធនានាកំណត់នូវវិវឌ្ឍនភាពក្នុងការគ្រប់គ្រងរបស់ពួកគេ ។ វិធាននេះខ្លី មិនសាំញ៉ាំ និងអាចប្រើប្រាស់ដោយងាយដើម្បីជួយបង្ហាញពីភាពរីកចំរើន និងកង្វះខាតដែលត្រូវដោះស្រាយ ។

ការដាក់ពិន្ទុមិនតម្រូវឱ្យមានការប្រមូលទិន្នន័យបន្ថែម។ ការវាយតំលៃអាចត្រូវបានអនុវត្តដោយអ្នកពាក់ព័ន្ធសំខាន់ៗ និងអ្នកគ្រប់គ្រងក្នុងតំបន់។ ខណ្ឌរដ្ឋបាលជលផលព្រះសីហនុ ក្រោមកិច្ចសហការជាមួយគម្រោង ICM បានអនុវត្តការតាមដានដោយប្រើប្រាស់វិធាន METT កាលពីពាក់កណ្ដាលឆ្នាំ២០១៧ និងឆ្នាំ២០២០ ដើម្បីវាយតំលៃលើវិវឌ្ឍនភាពតំបន់គ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ ។

## • ការវាយតម្លៃពីសុខភាពព្រៃកោងកាងៈ

ដើម្បីវាស់វែងអំពីសុខភាព គុណភាព ការលូតលាស់ និងអត្ថប្រយោជន៍របស់ព្រៃកោងកាង។ ការវាយតម្លៃអាចធ្វើទៅបានដោយប្រើឧបករណ៍ Field Survey និង Satellite ធ្វើការអង្កេត និងផ្ទៀងផ្ទាត់ជាមួយទិន្នន័យគោល ជាដើម។

## • ឧបករណ៍ BlueDiagnosis ការវាយតម្លៃប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់ការពារសមុទ្រ (MPA)៖

គឺជាជំហានដំបូងឆ្ពោះទៅរកនិរន្តរភាពក្នុងសកម្មភាពអភិរក្ស។ សម្រាប់អ្នកគ្រប់គ្រង Blue Diagnosis គឺជាឧបករណ៍ដែលត្រូវបានបង្កើតឡើងដោយ BlueSeeds ដើម្បីវាយតម្លៃប្រសិទ្ធភាព នៃការគ្រប់គ្រងនៃតំបន់ការពារដែនសមុទ្រ។ សាមញ្ញ និងរហ័សក្នុងការប្រើប្រាស់ Blue Diagnosis ផ្ដល់នូវរូបភាពរួមនៃសុខភាពរបស់ MPA របស់អ្នក តាមទស្សនៈនៃការគ្រប់គ្រងរបស់វា និងកំណត់ចំណុចខ្លាំង និងផ្នែកសម្រាប់ការកែលម្អ។

## • ការតាមដានទីជម្រកៈ

ការសិក្សាស្រាវជ្រាវអំពីប្រភេទព្រៃកោងកាង និងជីវចំរុះក្នុងតំបន់គ្រប់គ្រងជលផលព្រែកកំពង់ស្មាច់ នៅឆ្នាំ២០១១ ដើម្បីកំណត់នូវប្រភេទព្រៃកោងកាង និងទំហំដង់ស៊ីតេ និងកំណត់រកប្រភេទជីវៈចំរុះ នៅក្នុងតំបន់ព្រៃកោងកាង។

## • ការអង្កេតអំពីចំណេះដឹង ជំនាញ និងឥរិយាបទៈ

ការអង្កេតអំពីចំណេះដឹង ជំនាញ និងឥរិយាបទនឹងក្លាយជាវិធីសាស្ត្រមួយសម្រាប់តាមដានការផ្លាស់ប្ដូរសង្គមក្នុងចំណោមសហគមន៍នេសាទក្នុងតំបន់ព្រែកកំពង់ស្មាច់ និងជួយផ្ដល់ព័ត៌មានបន្ថែមសម្រាប់ការវាយតំលៃប្រចាំខែ ។

## • ការតាមដានសេដ្ឋកិច្ចសង្គមៈ

ដើម្បីតាមដាន និងវាយតំលៃវិវឌ្ឍនភាពសម្រាប់ទស្សនវិស័យ និងគោលដៅពាក់ព័ន្ធនឹងជីវសាស្ត្រសេដ្ឋកិច្ចសង្គម និងអភិបាលកិច្ច ការវាយតំលៃមួយនឹងត្រូវបានអនុវត្ត។ ការវាយតំលៃសេដ្ឋកិច្ចសង្គមជាផ្នែកមួយនៃកម្មវិធី ដើម្បីគាំទ្រដល់ក្រុមការងារនិងប្រើប្រាស់ ជាប្រយោជន៍សម្រាប់ ការគ្រប់គ្រងតំបន់តាមដាន និងវាយតំលៃប្រសិទ្ធភាពនៃអន្តរាគមន៍នានាសម្រាប់ការចិញ្ចឹមជីវិត និងសុខមាលភាពរបស់សហគមន៍តំបន់ឆ្នេរ ជីវចម្រុះ និងធនធានសមុទ្រ។

## • ការតាមដានផ្នែកអភិបាលកិច្ច៖

ឧបករណ៍តាមដាន និងរាយការណ៍រូបវន្ត (SMART) គឺជាគ្រប់ គ្រងមួយរៀបចំឡើងដោយមានកិច្ចសហការពីអ្នកពាក់ព័ន្ធនានាក្នុងវិស័យអភិរក្ស។ ឧបករណ៍នេះ ត្រូវបានប្រើប្រាស់សម្រាប់វាស់វែង វាយតំលៃ និងលើកកំពស់ប្រសិទ្ធភាពការអនុវត្តច្បាប់ និងល្បាត និងសកម្មភាពអភិរក្សក្នុងតំបន់ ។ ឧបករណ៍ SMART គឺជាឧបករណ៍មួយដែលអ្នកអាចទាញយកមកប្រើប្រាស់ដោយងាយ មិនចាំបាច់បង់ថ្លៃ និងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុងការការពារព្រៃឈើ នៅប្រទេសកម្ពុជា និងអភិរក្សបឹងទន្លេសាប ។ ទិន្នន័យត្រូវបានប្រមូលតាមរយៈការកត់ត្រាអំពីទីតាំង (GPS) និងចំណុចដែលបានកត់ត្រានៅតាមកន្លែងនានា ដែលមន្ត្រីល្បាត ឬក្រុមល្បាតសហគមន៍ដែលបានជួបប្រទះ បន្ទាប់មកទិន្នន័យទាំងនេះ ត្រូវបានបញ្ចូនទៅក្នុងផ្នែកទន់នៃកម្មវិធី SMART និងត្រូវបានប្រើប្រាស់សម្រាប់ផលិតផែនទី និងរបាយការណ៍។ របាយការណ៍ ទាំងនេះនឹងត្រូវបានផ្តល់ជាព័ត៌មានសម្រាប់ភ្នាក់ងារអ្នកអនុវត្តន៍ច្បាប់នៅក្នុងមូលដ្ឋាន ភ្នាក់ងារល្បាត ក្រុមល្បាតរបស់សហគមន៍ និងអ្នកគ្រប់គ្រងការអភិរក្ស ដើម្បីបន្សាំការគ្រប់គ្រងទៅតាមករណីទាំងនោះ និងការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតប។

## ឯកសារយោង៖


១.ក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល (វគ្គ២)៖ ២០១៥-២០២៤

២. ក្រុមការងារបច្ចេកទេស (២០១៩) ផែនការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលនៅព្រែកកំពង់ស្មាច់ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ២០១១៩ - ២០២៣

៣. រាជរដ្ឋាភិបាលកម្ពុជា (២០១៩) សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលស្តីពី គោលការណ៍គន្លឹះក្នុងការគ្រប់គ្រងជលផលសមុទ្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា (សថក ០១)

៤. រាជរដ្ឋាភិបាលកម្ពុជា (២០១៣) ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤ - ២០២៣

៥. គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងជីវៈចម្រុះព្រៃកោងកាងប្រកបដោយនិរន្តរភាព រៀបចំដោយ IUCN and WWF Germany


## ករណីសិក្សា / បទពិសោធន៍៖

តំណលីងខាងក្រោម ជាឯកសារករណីសិក្សា និងផែនការនានា ដែលពាក់ព័ន្ធការអនុវត្តការគ្រប់គ្រងតំបន់ការពារ និងតំបន់ការសមុទ្រ ដែលអ្នកគ្រប់គ្រង និងក្រុមការងារគ្រប់គ្រងជលផលសមុទ្រព្រែកកំពង់ស្មាច់ អាចរៀនសូត្រពីឯកសារទាំងនេះ សម្រាប់បង្កើនចំណេះដឹង និងបន្ថែមទៅលើការអនុវត្តជាក់ស្តែង។

**CASE STUDY 1:** Taklong Island National Marine Reserve (TINMAR), Guimaras, Philippines. https://www.apn-gcr.org/wp-content/uploads/2020/09/4d31a312d25053a4141fadce60bd2160.pdf

**CASE STUDY2:** Assigning IUCN Protected Area Management Categories – The Bahamas Experience. https://production-new-commonwealth-files.s3.eu-west-2.amazonaws.com/s3fs-public/2022-02/Case%20Study-%20Assigning%20IUCN%20Protected%20Area%20Managemen t%20 Categories%20%E2%80%93%20The%20Bahamas%20Experience.pdf

**CASE STUDY 3:** Aquaculture and Marine Protected Areas: https://portals.iucn.org/library/sites/library/files/documents/Rep-2017-003.pdf

**CASE STUDY 4:** Increasing the Resilience of Marine Ecosystems: Creating and Managing Marine Protected Areas in the Philippines. https://www.marineconservationphilippines.org/wp-content/uploads/2018/02/marine-protected-areas-in-the-philippines.pdf

**CASE STUDY 5:** Success indicators of marine protected areas in the Philippines: **A systematic review**
https://www.marineconservationphilippines.org/wp-content/uploads/2018/02/marine-protected-areas-in-the-philippines.pdf